# ការលើកទឹកចិត្តវិនិយោគ

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
ក្រុមការងារសម្របសម្រួល
ការទូតសេដ្ឋកិច្ច

## » អត្ថប្រយោជន៍ភូមិសាស្ត្រ

ជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចបើកចំហរបំផុតក្នុងតំបន់អាស៊ីអាគ្នេយ៍ និងមានទីតាំងស្ថិតនៅចំកណ្តាលនៃតំបន់ដែលប្រកបទៅដោយសក្តានុពល




### អាស៊ាន+៦ (RCEP)

ចំនួនប្រជាជនសរុប ៣,៥៨ ពាន់លាននាក់

| ផ.ស.ស ២៧,៣ ទ្រីលាន ដុល្លារអាមេរិក | ៣២,២% នៃសេដ្ឋកិច្ច ពិភពលោក | ២៩,២% នៃពាណិជ្ជកម្ម ពិភពលោក |
|---|---|---|

### អាស៊ាន

ចំនួនប្រជាជនសរុប ៦៤៩,១ លាននាក់

| ផ.ស.ស ២,៩៨ ទ្រីលាន ដុល្លារអាមេរិក | កំណើនសេដ្ឋកិច្ច ៥,១១% | ការវិនិយោគសរុប ១៥៤,៧ ពាន់លាន ដុល្លារអាមេរិក |
|---|---|---|

ទិន្នន័យឆ្នាំ២០១៩

### CLMTV

ចំនួនប្រជាជនសរុប ២៣៩ លាននាក់

| ផ.ស.ស ៨៦៦ ពាន់លាន ដុល្លារអាមេរិក | កំណើនសេដ្ឋកិច្ច ៦,៣៦% | ការវិនិយោគសរុប ៣៦,៧ ពាន់លាន ដុល្លារអាមេរិក |
|---|---|---|

ទិន្នន័យឆ្នាំ២០១៩

## » ការលើកទឹកចិត្តក្នុងការវិនិយោគ

### ១ ការលើកទឹកចិត្តជាមូលដ្ឋាន

**ជម្រើសទី១**

- ការលើកលែងពន្ធលើប្រាក់ចំណូលសម្រាប់រយៈពេលពី ៣ ទៅ ៩ឆ្នាំ
- អត្រាពន្ធលើប្រាក់ចំណូលក្រោយរយៈពេលលើកលែង៖
  - ២៥% សម្រាប់រយៈពេល ២ឆ្នាំ
  - ៥០% សម្រាប់រយៈពេល ២ឆ្នាំ បន្ទាប់
  - ៧៥% សម្រាប់រយៈពេល ២ឆ្នាំ ចុងក្រោយ។

**ជម្រើសទី២**

- រំលស់ពិសេស
- មានសិទ្ធិកាត់កងរហូតដល់ ២០០% លើចំណាយជាក់លាក់ផ្សេងៗ

**ជម្រើសទាំងពីរ**ខាងលើនឹងទទួលបានការលើកទឹកចិត្តបន្ថែមទៀតដូចជា៖

- ការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ក្នុងកំឡុងពេលលើកលែងពន្ធលើប្រាក់ចំណូល
- ការលើកលែងពន្ធអប្បរមា ដោយត្រូវមានរបាយការណ៍សវនកម្មឯករាជ្យ
- ការលើកលែងពន្ធអាករនាំចេញ

**ការលើកលែង៖** ការទទួលបានការលើកលែងទៅលើពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម សម្រាប់ការនាំចូលនូវសម្ភារៈសាងសង់ បរិក្ខារសំណង់ និងសម្ភារៈបរិក្ខារផលិតកម្ម

### ២ ការលើកទឹកចិត្តបន្ថែម

- ទទួលបានការលើកលែងអាករលើតម្លៃបន្ថែម ចំពោះការទិញធាតុចូលដែលផលិតក្នុងស្រុក
- ទទួលបានការកាត់កងចំណាយក្នុងអត្រា ១៥០% ពីមូលដ្ឋានគិតពន្ធចំពោះ៖
  - (ក) ការស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍
  - (ខ) ការអភិវឌ្ឍធនធានមនុស្ស តាមរយៈការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ
  - (គ) ការសាងសង់កន្លែងស្នាក់នៅ កន្លែងបរិភោគអាហារ និងទារកដ្ឋាន ឬកន្លែងផ្សេងទៀត
  - (ឃ) ការធ្វើទំនើបកម្មលើគ្រឿងម៉ាស៊ីន និង
  - (ង) ការផ្តល់ការលើកកម្ពស់សុខុមាលភាពដល់កម្មករនិយោជិតខ្មែរ។
- ការលើកលែងពន្ធលើប្រាក់ចំណូលចំពោះការពង្រីកគ.ល.គ

### ៣ ការលើកទឹកចិត្តពិសេស

- នឹងត្រូវផ្តល់ជូនដល់វិស័យ និងសកម្មភាពវិនិយោគជាក់លាក់ណាមួយ ដែលមានសក្តានុពលខ្ពស់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ (ត្រូវបានកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង)។